# ការសំភាសន៍របស់បងស្រី កែវ ស្រីនាង

កៈ អ្នកសំភាសន៍គេឈ្មោះ រត្ន ស្រីភាព ខៈ អ្នកដែលគេបានសំភាសន៍ កែវ ស្រីនាង

កៈ ជាដំបូងនាងខ្ញុំសុំជំរាបសួរនាង្ខំឈ្មោះរត្ន ស្រីភាពសុំធ្វើកាលសំភាសន៍ជីវះប្រវិត្តរបស់បងស្រីនៅពេលដែលខ្ញុំធ្វើសំភាសន៍និងគឺខ្ញុំធ្វើឡើងដោលសាលារៀនមួយដែលមានឈ្មោះថាសាលា b y u ដែលនៅអាមេរិចណាបងស្រីហើយដើម្បីថៃជីវះប្រវិត្តជូនតារបស់បងស្រីនិងថៃរសាជីវះប្រវត្តិបងស្រីទុកអោយកូនក្មេងជំនាន់ក្រោយៗអោយគេបានដឹងថាជីវះប្រវត្តិរបស់អ្នកជំនាន់មុនពួកគេលំបាកអីខ្លះពីមួយជំនាន់ទៅមួយជំនាន់ណាបងហើតខ្ញុំបញ្ជាប់ថាកាលសំភាសន៍ធ្វើនៅថ្ងៃទី ខែ ឆ្នាំ

កៈ ចាំចឹងបងស្រីមានឈ្មោះអីដែលបងស្រី?

ខៈ ខ្ញុំឈ្មោះកែវ ស្រីនាង ។

កៈ ចាំចឹងបងមានឈ្មោះហៅខាងក្រៅទេបង?

ខៈ នៅខាងក្រៅគេតែងតែហៅខ្ញុំស្រីឈិតៗ។

កៈ ចាំចឹងសព្វថ្ងៃនិងបងស្រីនាងមានអាយុប៉ុន្មានដែលបងស្រីនាង?

ខៈ ខ្ញុំមានអាយុ៣៩ឆ្នាំហើយខ្ញុំ។

កៈ ចឹងបងអាយុ៣៩ឆ្នាំហើយដូចជាបងមានបានចាំថ្ងៃខែឆ្នាំកំណើតរបស់បងដែលទេបង?

ខៈ ខ្ញុំចាំខ្ញុំបានណើតនៅឆ្នាំ១៩៨១ ។

កៈ ចឹងបងស្រីកើតនៅឆ្នាំ១៩៨១ ហើយខែបងមានចាំទេបង?

ខៈ ខ្ញុំកើតនៅមេសា?

កៈ ចាំបងកើតនៅខែមេសាគេហៅខែ៤ចុះថ្ងៃអីបងមានចាំទេបង?

ខៈ ខ្ញុំចាំថ្ងៃអង្គារ៍។

កៈ ចឹងបងបានកើតនៅថ្ងៃអង្គារ៍ចឹងបងនែំហើយដូចជាឆ្នាំការគិតអីដូចជាជូត ឆ្លូវ ថោល អីនិងតើបងមានចាំឆ្នាំណាទេបង?

ខ៖ ខ្ញុំបានកើតចំឆ្នាំរកា។

ក៖ ចឹងបងបានកើតចំឆ្នាំរកា៕

ខ៖ ចាំ!

ក៖
ចុះទីកន្លែងកំណើតនិងបងបានកើតបៅណានៅណាដែលបងដូចជាស្រុកកំណើតនិងបង?

ខ៖ ខ្ញុំបានក់តនៅជំរុងសែនធូ ។

ក៖ បងបានកើតនៅជំរុងសែនធូនៅណាដែលបង?

ខ៖ នៅសង្កាត១៣នៅភូមិដើមចាន់?

ក៖ នៅខែកណ្តាយឬក៏នៅទីក្រុងភ្នំពេញយើងបងស្រី?

ខ៖ អត់ទេៗ នៅជាដែនថៃ។

ក៖ ចឹងបងពីមុនបងបាននៅជាដែនថៃ?

ខ៖ ចាំខ្ញុំពីមុននិងខ្ញុំបាននៅជាដែនថៃនិង។

ក៖ នៅជាដែនថៃនិងបងស្រីបានជាដែនថៃនិបបងបាន
នៅខាងប៉ោយបែតឬបងនៅខាងបាត់ដំបង់វិញបង?

ខ៖
ខ្ញុំបាននៅជាយឯងនែ់វិញទេមិនបាននៅខាងនិងទេខ្ញុំនៅខាងជាដែនខាងដងរែកវិញទេមិនបាននៅនិងទេពីមុនមកនិង។

ក៖
ចឹងបងបាននៅខាងដងរែកនិងទេហើយនៅខាងសែនធូនិងខ្ញុំដូចជាបានធ្លាក់លឺចឹងបងបានផ្លាក់មកនៅទីក្រុមភ្នំពេញនិងតាំងពីពេលណាដែលបង?

ខ៖ អឺ!ខ្ញុំបានមកនៅភ្នំពេញនិងបានទៅដល់២៥ឆ្នាំហើយ។

ក៖ ហើយបងបានមកនៅទីក្រុមភ្នំពេញនិងពីដំបូងនិងកន្លែងណាដែលបង?

ខ៖ ខ្ញុំកដល់ដំបូងខ្ញុំមកនៅនោះ?

ក៖ នោះនិងនៅណាបងស្រីខ្ញុំមិនយល់អំពីអ្វីដែលបងបាននិយាយទេ?

ខ៖ មកនៅកន្លែងច្បារអំពៅនិងតែម្តងនិង។

ក៖
បងមកនៅនិងតែបងមកនៅខុសភូមិនិងតែបងបានមកនៅនិងយូរហើយបងមែនទេបង?

ខ៖ ខ្ញុំនៅខាងមុននិង។

ក៖
បន្តមកបងបានមកនៅនិងតែម្តងនិងទៅមកនៅនិងជារបស់ខ្លួនឯងឬជាកាលបងបានជួយគេបង?

ខ៖ ខ្ញុំនៅនិងខ្ញុំបាននៅជាមួយបងខ្ញុំ។

ក៖ ចឹងបងបាននៅនិងគឺបងបានមកនៅជាបងរបស់បងទេរាល់ថ្ងៃនោះ?

ខ៖ ខ្ញុំនៅនិងខ្ញុំបាននៅរួមគ្នា។

ក៖ ចាំៗបងបានមករស់នៅភូមិឬសង្កាត់អីដែលបង?

ខ៖ នៅនិងគេបានហៅសង្កាត់ច្បារអំពៅ។

ក៖ ចាំ ចឹងនៅនិងគេសង្កាត់ច្បារអំពៅដូចភូមិ យុណាអីបងបានដឹងទេបងភ្នំពេញ?

ខ៖ ចាំ!ខណ្ឌជ្រាប់បាក់។

ក៖ ចាំចឹងគេបានហៅថាទីនិងខណ្ឌចជ្រាប់បាក់ ហើយរាជធានីភ្នំពេញវិញចឹងបងស្រី?

ខ៖ ចាំ!

ក៖
ចាំចឹងតើក្រុមគ្រួសាររបស់បងស្រីដែលគេហៅថាជាសមាជិតនិងមានប៉ុន្មាននាក់ដែលបងស្រី?

ខ៖ ខ្ញុំមានបងប្អូនខ្ញុំទាំងអស់៨នាក់ស្រី៤ប្រុស៤នាក់និបបងប្អូនខ្ញុំ។

ក៖ ហើយបងជាកូនទីប៉ុន្មាន់ដែលបង?

ខ៖ ខ្ញុំជាកូនទី៥។

ក៖
អូ!ចាំបងស្រីបងជាកូនទី៥ហើយបងមានចាំថាកូនបងទាំងអ្នកនិងបងប្អូនរបស់បងគាត់មា

នឈ្មោះអីដែលទេបងហើយបងអាចប្រាប់ខ្ញុំអំពីឈ្មោះបងប្អូនរបស់អោយខ្ញុំបានស្គាល់ផងបានទេបង?

ខ៖ ទីមួយស្រីលីន ស្រីជឿង ។

ក៖ អីទៀតបង?

ខ៖ បងរត្ន បងរី ស្រីខូច ខ្ញុំនិងស្រីនាង ហើយងឹត ហើយបងខ្ញុំរុធអស់ហើយ

ក៖ ចាំសារបងបានប្រាប់ខ្ញុំអស់ហើយ?

ខ៖ ចាំ

ក៖ ចឹងពួកគាត់និងបានរស់នៅទាំងអស់គ្នាបង?

ខ៖ ចាំគាត់បាននៅរស់ទាំងអស់គ្នា។

ក៖
ចឹងសព្វថ្ងៃនិងពួកគាត់នៅរស់ទាំងអស់គ្នាតែពួកគាត់បានរស់នៅកន្លែងខុសគ្នាៗនេំបង?

ខ៖ ចាំ!

ក៖ចឹងបងអាចប្រាប់ខ្ញុំបានទេកាលដែលបងបាននៅពីក្មេងៗបងដែលមានអានុស្សាវរីយ៍អីខ្លះដែលបងបាននៅពីក្មេងៗជាមួយគ្នាដែលបង?

ខ៖
ខ្ញុំធ្លាក់បាននៅនិយាយជាមួយគាត់ហើយខ្ញុំនិយាយរួមទៅខ្ញុំបានធ្វើអីដែលអោយគាត់បានសប្បាយចិត្តច្រើនខ្ញុំតែងតែពយ្យាមធ្វើកាលដែលគាត់អាចប្រើខ្ញុំបានខ្ញុំទេងទេខំធ្វើកាលងារនិងអោយរួចខ្ញុំនិងដេលហាននខ្ជិលទេ។

ក៖
ចឹងបងជាកូនទី៥ក្នុងគ្រួសារនិងដែលបងប្អូនទាំងអស់គ្នាពួកគេដែលចូលចិត្តហើយយកចិត្តទុកដាក់ជាងគេណាបង?

ខ៖
ចាំ!ទីមួយគាត់បានមកចឹងគាត់តែងតែសួរខ្ញុំថាបានញុំាបាយរួចនៅចឹងខ្ញុំបានប្រាប់គាត់ថាខ្ញុំបានញុំារួចហើយ ហើយគាត់តែងតែអោយលុយខ្ញុំចាយទៀត។

ក៖
ចាំ!ដោយសារគាត់អាណិតស្រលាញ់បងជាងគណាស់ចាំនឹងហើយមួយបងប្អូនទាំងអស់ចាំហើយខ្ញុំសូមអធស្រ័យមានតែបងទេដែលមានរូបរាងខុសគេណាស់បង?

ខ៖
ចាំ!ប៉ុន្តែមកពីកំណើតមកពីម៉ែរបស់ខ្ញុំគាត់ខឹងឪពុកខ្ញុំម៉ាក់ខ្ញុំគាត់ទៅលេបថ្នាំសម្លាប់ខ្លួនទៅគាត់ស្មានតាគាត់នឹងអត់ទាន់មានខ្ញុំ។

ក៖
ចាំ!ចឹងជាមូលហេតុដែលបងមកដល់ថ្នាក់នឹងមកពីអ្នកម្ដាយរបស់បងគាត់បានទៅលេបថ្នាំសម្លាប់ខ្លួនចឹងទៅហើយគាត់អត់បានដឹងថាបងបានមកចាប់កំណើតនៅក្នុងពោះគាត់ទេចាំចឹងជាមូលហេតុដែលបងមានរូបរាងមិនប្រក់ក្រដីចឹងណាស់បងតែខ្ញុំថាវាមិនអ្វីទេចាំចឹងបងអាចប្រាប់ខ្ញុំបានបន្តិចបានទេថាបងមានកាងារអ្វីខ្លះដែលបងចូលចិត្តធ្វើការជាមួយបងប្អូនបងណាស់បង?

ខ៖ ខ្ញុំចូលចិត្តធ្វើការជាមួយពួកគាត់គឺខ្ញុំចូលចិត្តធ្វើកិច្ចការផ្ទះដូចជាបោះផ្ទះ បោកខោអាវ។

ក៖
ចាំ!នឹងហើយគឺបងចូលចិត្តធ្វើការជាមួយពួកគាត់នឹងហើយចាំចុះសព្វថ្ងៃនឹងតើពួកគាត់មានរស់នៅឯណាខ្លះដែលសម្រាប់ក្រុមគ្រួសារបងទាំងប៉ុន្មានដែលបង?

ខ៖ នៅនេះខ្លះនៅនោះខ្លះ។

ក៖ ចាំ!បងនៅណាដែលបងដូចជានៅភូមិណាដែលបង?

ខ៖ នៅភូមិជាមួយគ្នាតា។

ក៖ ចាំ!តែគ្រាន់តែឈ្រោស់ផ្ទះគ្នាទេណាស់បង?

ខ៖ ចាំ!តែមួយទៀតគេនៅក្រៅប្រទេសនឹងគាត់ជាប្អូនពៅរបស់ខ្ញុំ។

ក៖ ចាំ!គាត់នៅប្រទេសណាដែលបង?

ខ៖ គាត់នៅប្រទេសបារាំង។

ក៖ ចាំ!ទៅដល់ប្រទេសបារាំងបង?

ខ៖ ចាំ!ហើយនៅនឹងដល់ទៅពីនាក់បងស្រីមួយនាក់ហើយនឹងប្អូនស្រីម?យយនាក់ដែល។

កៈ
ចា៎!ហើយបន្តបមកបងមានបងប្អូននៅភូមិបាក់សង្កាត់ច្រាង់បាក់នឹងបងចា៎ហើយនៅនឹងមានចំនួនប៉ុន្មាននាក់ដែលបង?

ខៈ នៅនឹងមានចំនួន៧នាក់។

កៈ ចា៎!នៅនឹងចំនួន៧នាក់ចា៎ហើយបងមានប្អូននៅក្រៅប្រទេសពីរនាក់ទៀត?

ខៈ ចា៎!

កៈ ចា៎!ចឹងនៅទីនេះមានតា៥នាក់តាបង?

ខៈ ចា៎!

កៈ
ចា៎!ចឹងនៅក្រៅប្រទេសដល់តែពីរនាក់នៅស្រុកខ្មែរ៥នាក់ហើយក៏នៅក្នុងភូមិច្រាង់បាក់នឹង៥នាក់ដែលនិយាយអោយចំទៅបងប្អូនអ្នកមីងទាំង៥នាក់និងនៅក្នុងភូមិតែមួយជាមួយបងនឹង?

ខៈ ចា៎!

កៈ តែគ្រាន់តែផ្ទះគាត់នៅមុខនិងខាងក្រោយ?

ខៈ ចា៎!

កៈ
ចា៎!ចឹងបងអាចប្រាប់ខ្ញុំបន្តិចបានទេពីលោកឪពុកហើយនឹងអ្នកម្តាយរបស់បងតើបងអាចប្រាប់ខ្ញុំអំពីឈ្មោះរបស់ពួកគាត់បានទេបង?

ខៈ គាត់មានឈ្មោះថា កែវ ស៊ីថាត់។

កៈ ចា៎!តើគាត់ជាលោកឪពុកឬមួយជាអ្នកម្តាយខែលបង?

ខៈ គាត់ជាម្តាយរបស់ខ្ញុំ។

កៈ ចា៎!ហើយចុះលោកឪពុករបស់បងវិញ?

ខៈ លោកឪពុកខ្ញុំគាត់មានឈ្មោះថា គង់ ចុងជីង។

ក៖ ចាំ!លោកឪពុករបស់បងគាត់មានឈ្មោះថាលោកព្ធ គង់ ខ្ទុងជឹងចាំហើយសព្វថ្ងៃនឹងតើគាត់នៅរស់ទេបង?

ខ៖ គាត់នៅរស់ទេ។

ក៖ ចាំ!ហើយគាត់នៅរស់ទាំងពីរនាក់បង?

ខ៖ ចាំ!

ក៖ ចាំ!ហើយចុះបើលលោកឪពុកនឹងអ្នកម្តាយបងនៅរស់តើគាត់មានអាយុប៉ុន្មានហើយដែលបង?

ខ៖ លោកឪពុកខ្ញុំគាត់មានអាយុប្រហែល៧០ជាងហើយ។

ក៖ ចាំ!ហើយចុះអ្នកម្តាយរបស់បងវិញបង?

ខ៖ អ្នកម្តាយរបស់ខ្ញុំវិញគាត់មានអាយុ៥០ជាងហើយ។

ក៖ ចាំ!ហើយឥឡូវនឹងតើពួកគាត់រស់នៅណាដែលបង?

ខ៖ លោកឪពុកខ្ញុំគាត់នៅស្រុកម្តាយរបស់ខ្ញុំរស់នៅក្រៅប្រទេស។

ក៖ ចាំ!ម្តាយរបស់បងគាត់ទៅរស់នៅក្រៅប្រទេសដែល?

ខ៖ ចាំ!នៅជាមួយបង។

ក៖ ចាំ!នៅជាមួយបងស្រីចាំដូចជាលោកឪពុកបងនៅស្រុកនឹងដូចជានៅខាងណាដែលបង?

ខ៖ គាត់នៅកំពុងចាម។

ក៖ ចាំ!គាត់នៅខាងកំពុងចាមចាំហើយគាត់នៅម្តុំណាដែលវិញបង?

ខ៖ នៅជាបរិហាបង។

ក៖ ចាំ!នៅជាប់វិហានៅខេត្តកំពុងចាមនឹងបង?

ខ៖ ចាំ!

ក៖ ចាំ!ហើយគាត់នៅសាខាទីប៉ុន្មានដែលបង?

ខ៖ គាត់នៅសាខាទីមួយនឹង។

ក៖ ចាំ!ចឹងមានន័យថាគាត់រស់នៅខាងផ្សារបឹងគុក?

ខ៖ នឹងហើយ។

ក៖
ចាំ!ចឹងលោកឪពុករបស់បងគាត់នៅម្តុំផ្សារបឹងគុកណាស់បងចាំនៅខេត្តកំពុងចាមនឹងចាំចឹងបងអាចប្រាប់ខ្ញុំបានបន្តិចថាបងមានបានចាំថ្ងៃខែឆ្នាំកំណើតរបស់លោកឪពុកនឹងអ្នកម្តាយរបស់បងបានទេ?

ខ៖ ចាំ!តែខ្ញុំចាំថាម៉ាក់របស់ខ្ញុំ?

ក៖ ចាំ!ហើយចុះម៉ាក់របស់បងតើគាត់កើតនៅថ្ងៃណាខែឆ្នាំណាដែលបង?

ខ៖ គាត់កើតនៅខ្ញុំដូចជាចង់ភ្លេចហើយ។

ក៖ ចាំ!មិនអីទេចាំចុះបើលឆ្នាំខ្មែរវិញដូចជាឆ្នាំ ជូត ឆ្លូវ ខាល អីតើអ្នកម្តាយរបស់បងគាត់កើតនៅឆ្នាំណាដែលបង?

ខ៖ បើលឆ្នាំនឹងម៉ាក់ខ្ញុំគាត់កើតឆ្នាំ កុល។

ក៖ ចាំ!គាត់កើតឆ្នាំកុលចាំហើយចុះអ្នកម្តាយរបស់បងវិញ?

ខ៖ ខ្ញុំអត់បានចាំទេខ្ញុំភ្លេចបាត់ហើយ។

ក៖
អរចាំ!ចឹងចំពោះគាត់ដូចថាបងកាលនៅពីបងនៅក្មេងៗណាស់បងតើលោកឪពុកហើយនឹងអ្នកម្តាយរបស់បងមានប្រកបមុខរបរអ្វីចិញ្ចឹមបងដែលបង?

ខ៖ កាលគាត់នៅថៃគាត់ជាអ្នកលក់ផ្លែឈើ។

ក៖ ចាំ!គាត់ជាអ្នកលក់ផ្លែឈើបង?

ខ៖ ចាំ!

ក៖
ចាំ!ហើយបងប្រើជីវិត្តអស់រយះពេលប៉ុន្មានឆ្នាំដែលកាលបងរស់នៅប្រទេសថៃមកកាលបងនៅក្មេងៗបង?

ខ៖ ៣ទៅ៤ឆ្នាំហើយ។

ក៖
អរចាំ!៣ទៅ៤ឆ្នាំហើយចាំហើយបងបានមកផ្លាស់មកនៅប្រទេសកម្ពុជាវិញនឹងអស់រយះពេល២០ឆ្នាំហើយចាំចឹងបងរស់នៅនឹងតាំងពីបងនៅពីក្មេងមកម្លេះចាំចឹងបងអាចប្រាប់ខ្ញុំបានទេថាលោកឪពុកនឹងអ្នកម្តាយរបស់បងគាតទៅលក់ផ្លែឈើនៅប្រទេថៃនឹងតើគាត់លក់នៅម្តុំណាដែលបង?

ខ៖ នៅផ្សារថៃ។

ក៖ នៅក្នុងផ្សារថៃនឹង?

ខ៖ ចាំ!

ក៖ ចាំ!ហើយសម្រាប់បងតើបងគិតថាពួកគាត់ទាំងពីនាក់នឹងជាមនុស្សបែបណាដែលបង?

ខ៖
មនុស្សគាត់អត់ខូលខិវដូចម៉ែអស់គេទេគាត់ស្លូតទីមួយគាត់អត់ចេះក្បាត់ប្រពន្ធអត់អីអត់ចេះចឹងណាស់ទាំងអស់។

ក៖ គាត់អត់ចេះភិតក្បាត់ជាមួយប្តីប្រពន្ធទេ?

ខ៖ ចាំ!

ក៖
ចាំ!ហើយលោកឪពុករបស់បងមិនដែលឲ្យម្តាយរបស់បងពិបាកចិត្តឡើយចាំនឹងជាអ្វីដែលបងចង់និយាយណាស់ហើយចុះសម្រាប់បងរស់នៅជាមួយគាត់ណាស់តើបងបានដឹងពីជីវិត្តថាបងរស់នៅជាមួយគាត់ដោយបែកណាហើយមានការកំសត់អ្វីខ្លះជាមួយនឹងគ្នាណាស់បង?

ខ៖
ដូចជាប្តីប្រពន្ធគាត់ភាពច្រើនខ្ញុំសង្កាត់មើលគាត់ណាស់គាត់មិនដែលវៃតបគ្នាទេនិយាយរួមទៅពួកគាត់មានអីចេះចែកគ្នាហូបហើយម៉ាក់ខ្ញុំអីគាត់បានអីក៏គាត់ទុកអោយប៉ាខ្ញុំហូបដែល។

ក៖
ចាំ!ចឹងមានន័យថាក្រុមគ្រួសាររបស់បងដូចជាមិនមានអ្វីដែលវាពិបានខ្លាំងទេចាំហើយចុះបងមានបានចាំសាច់រឿងអ្វីខ្លះចំពោះលោកឪពុកហើយនឹងអ្នកម្តាយរបស់បងទេដូចជាកា

លគាត់នៅពីក្មេងៗណាស់បងដូចជាគាត់មានបានប្រាប់ពីដំណើរជីវិត្តរបស់គាត់ទៅកាន់បងទេ?

ខ៖ គាត់ថាម៉ារបងប្អូនទាំងអស់មានតាគាត់ទេដែលនឿយហាត់ជាងគេ។

ក៖ ចាំ!ហើយបងមានបានដឹងថាគាត់ហាត់នឿយដោយសារអ្វីដែលបង?

ខ៖
គាត់ថាគាត់នឹងកាត់ទៅតាមម៉ែរបស់គាត់ខ្ញុំមានតាប៉ុននឹងបើលប៉ាខ្ញុំវិញគាត់មិនដែលនិយាយទេ។

ក៖ ចាំ!ហើយគាត់មិនដែលនិយាយពីគាត់កាលនៅសម័យអាពត់អីទេបង?

ខ៖ ចាំ!គាត់ប្រាប់។

ក៖ ចាំ!ហើយបងមានចាំអ្វីខ្លះដែលបង?

ខ៖
គាត់បាននិយាយប្រាប់ខ្ញុំពីគាត់ថាពួកខ្ញុំសំណាងហើយបានបាយញុំានោះព្រោះគាត់អត់បានបាយទេគាត់ថាទល់តែធ្វើការហាត់បានតែបបរមួយវែកទេគាត់មិនបានបាយពិនទេបើលគាត់មានគាត់លួតលាក់ទៀតដល់ហើយខ្ញុំឮគាត់និយាយចឹងខ្ញុំគិតទៅពិបាកណាស់ខ្ញុំពិបាកចិត្តជំណួសគាត់។

ក៖ ចាំ!ដោយសារកាលជំនាន់នឹងមានភាពខ្វលខៅចឹងណាស់បង?

ខ៖ ចាំ!

ក៖
ចាំ!ចឹងតើសម្រាប់បងតើបងអាចប្រាប់ខ្ញុំបន្ថែបបានទេថាលោកតាលោកយាយរបស់បងណាស់តើបងមានបានស្គាល់ឈ្មោះពួកគាត់ទេបង?

ខ៖ ខ្ញុំស្គាល់តា។

ក៖ ចាំ!តាំងម្ខាក់ម្ដាយនឹងលោកឪពុកណាស់បង?

ខ៖ ចាំ!លោកយាយលោកតាអី។

ក៖ ចាំ!លោកយាយនឹងលោកតានឹងបង?

ខ៖ អរខ្ញុំស្គាល់តាខាងម៉ាក់ទេខាងប៉ាខ្ញុំមិនស្គាលតែ។

កៈ ចាំ!

ខៈ លោកយាយខ្ញុំគាត់មានឈ្មោះថា គិនលីលោកតាខ្ញុំគាត់ឈ្មោះលោកតា បូល។

កៈ ចាំ!តែឈ្មោះពួកគាត់នឹងគឺនៅខាងអ្នកម៉ាកបង?

ខៈ ចាំ!

កៈ ចាំ!ចំណែកខាងលោកឪពុកបងមិនស្គាល់ទេ?

ខៈ ចាំ!មិនស្គាល់ទេ។

កៈ ជាមូលហេតុអ្វីដែលបង?

ខៈ ខ្ញុំមិនបានសួរគាត់ផងនឹង។

កៈ ចាំ!ហើយក៏កើតមិនទាន់ពួកគាត់?

ខៈ ចាំ!ខ្ញុំកើតមិនទាន់ទេបើលម៉ាក់ខ្ញុំគាត់កើតទាន់។

កៈ ចាំ!បើលម៉ាក់បងគាត់កើតទាន់?

ខៈ ចាំ!

កៈ
ចាំ!ហើយចុះបើលសិនជាលោកតាលោកយាយខាងឪពុកម្តាយរបស់បងតើបងកើតទាន់ទេ?

ខៈ ខ្ញុំកើតអត់ទាន់ទេ។

កៈ
ចាំ!ហើយបើលបងកើតទាន់នឹងដូចជាមានចាំថាបើលបងរស់នៅជាមួយគាត់ណាស់តើពួកគាត់មានអាយុប៉ុន្មានខ្លះដែលទៅបង?

ខៈ គាត់ប្រហែលអរខ្ញុំភ្លេចហើយ។

កៈ ចាំ!បងភ្លេចហើយ?

ខៈ គាត់ចាស់ៗអស់ហើយ។

កៈ នឹងហើយបើលទល់មកដល់ពេលសព្វថ្ងៃនេះគាត់ប្រហែលជា ១០០ឆ្នាំហើយបងណាស់ចាំប៉ុន្តែពួកគាត់បានស្លាប់អស់ហើយចាំហើយចុះបងមានបានដឹងពីឆ្នាំខ្មែរដូចជាឆ្នាំ ខាល ជូត អីណាស់បងតើបងមានបានដឹងថាឆ្នាំណាខ្លះដែលទេបងសម្រាប់លោកតាលោកយាយរបស់បងណាស់បង?

ខៈ ខ្ញុំអត់បានសួរគាត់ផងនឹង។

កៈ ចាំ!ចឹងបងមានបានដឹងពីសាច់រឿងអ្វីពីគាត់ទេបង?

ខៈ ខ្ញុំអត់ដឹងផងខ្ញុំនិយាយត្រង់ម៉ងខ្ញុំអត់ដឹងទេណាមួយខ្ញុំអត់បានសួរមួយនឹងទៀត។

កៈ
ចាំ!មិនអីបងចាំចឹងដូចជាបញ្ហាក្រុមគ្រួសារបងផ្សេងៗទៀតរបស់បងណាស់បងដូចជាគាត់អ្នកនៅស្រុកខាងជាយដែនថៃណាស់បងតើគាត់រស់នៅនឹងតាំងពីជំនាន់លោកតាលោកយាយមកបង?

ខៈ កាលនឹងខ្ញុំមកនៅទីនេះយូរហើយប៉ុន្តែខ្ញុំទុបតែមកនៅទេ។

កៈ
ចាំ!ប៉ុន្តែលោកតាលោកយាយបងជាអ្នកនៅស្រុកកំណើតនៅជាយដែនថៃឬមួយអ្នកនៅស្រុកកំពុងចាម?

ខៈ គាត់ជាអ្នកនៅខេត្តកំពុងឆ្នាំង។

កៈ ចាំ!គាត់ជាអ្នកនៅកំបុងឆ្នាំងវិញតាំងជំនាន់លោកតាលោកយាយមក?

ខៈ ចាំ!គាត់នៅកំពុងឆ្នាំងបើលម៉ាក់ខ្ញុំគាត់មិនកើតនៅនឹងទេគាត់កើតនៅស្រុកក្រៅ។

កៈ ចាំ!

ខៈ នៅខេត្តកំពុងឆ្នាំងទាំងអស់។

កៈ
ចាំ!ប៉ុន្តែគាត់ទៅលក់ស៊ីនៅជាយដែនថៃហើយបន្ទាប់មកគាត់បានមកផ្លាស់ទីលំនៅមកនៅប្រទេសកម្ពុជាវិញ?

ខៈ ចាំ!

កៈ
ចាំ!ចឹងបងអាចប្រាប់ខ្ញុំម្ដងទៀតបានទេថាសាច់ញ្ញាតិរបស់បង៣នាក់ដែកគាត់រស់នៅប្រទេសបារាំងដូចជាអ្នកម្ដាយរបស់បងដូចជាបងស្រីរបស់បងនឹងប្អូនស្រីពៅរបស់បងដែលគាត់រស់នៅប្រទេសបារាំងណាស់?

ខៈ ចាំ!

កៈ ចាំ!ហើយតើបងមានបានចាំថាតើគាត់រស់នៅរដ្ឋណាដែលបង?

ខៈ គាត់រស់នៅបារីស។

កៈ ចាំ!គាត់រស់នៅបារីសចាំចឹងតើគាត់រស់នៅនឹងអស់រយះពេលប៉ុន្មានឆ្នាំហើយដែលបង?

ខៈ ទុបនៅបានប៉ុន្មានឆ្នាំនឹងទេ។

កៈ ចាំ!ទុបតែនៅបានប៉ុន្មានឆ្នាំងទេ?

ខៈ ចាំ!បងស្រីខ្ញុំនឹងគាត់ទៅយូរហើយ។

កៈ ចាំ!បងស្រីបងគាត់នៅនឹងយូរហើយ?

ខៈ ចាំ!តាំងពីខ្ញុំនៅក្មេងមកហើយ។

កៈ ចាំ!តើគាត់បានទៅដោយសារអ្វីដែលបងបានគាត់បានទៅដល់បង?

ខៈ គាត់ទៅដោយសារគាត់ទៅធ្វើការនៅនឹង។

កៈ អរចាំ!គាត់ធ្វើការនៅនឹងណាស់បង?

ខៈ ចាំ!

កៈ
ចាំ!គាត់បានធ្វើការទៅគាត់បានផ្លាស់ប្ដូរជីវិត្តគាត់ទៅហើយគាត់ក៏នៅក្នុងរដ្ឋបារីសនឹងទៅ?

ខៈ ចាំ!

កៈ
ចាំ!ចឹងតើបងអាចប្រាប់ខ្ញុំបន្ថែមទៀតថាជីវិត្តរបស់បងផ្ទាលណាស់តើបងធ្លាប់មានស្វាមីទេពីមុនមកបង?

ខៈ ខ្ញុំមានតាមានមួយនឹង។

កៈ ចាំ!ហើយស្វាមីរបស់បងនឹងតើគាត់មានឈ្មោះអ្វីដែលបង?

ខៈ គាត់មានឈ្មោះថា សុខ ខាក់រឿន។

កៈ ចាំ!គាត់មានឈ្មោះថា សុខ ខាក់រឿននឹងបង?

ខៈ នឹងហើយ។

កៈ ហើយចុះបងរៀបការជាមួយគាត់មកពីឆ្នាំណាដែលបង?

ខៈ ទុបតែឥឡូវនឹងដែលនឹង។

កៈ
ចាំ!ហើយឥឡូវៗនឹងប្រហែលប៉ុន្មានឆ្នាំដែលបងអាចស្មានបានទេប្លែលឆ្នាំណាដែលបង?

ខៈ កាលពីឆ្នាំ២០០៧មក។

កៈ
ចាំ!បងរៀបការជាមួយស្វាមីបងនៅឆ្នាំ២០០៧មកចាំចឹងបងបានរៀបការជាមួយគាត់អស់រយៈពេល១៧ឆ្នាំហើយចុះការរៀបការរបរបងនឹងតើពីណាគេជាអ្នកដែលរៀបចំអោយបងដែលបង?

ខៈ នៅខាងស្វាមីគាត់ជាអ្នករៀបចំអោយ។

កៈ
ចាំ!ហើយគរអោយបងទៅរៀបការនៅខាងគេទៅចាំហើយការបងមានចាំថាគេមានបានជូនថ្លៃទឹកដោះបងតើមានចំនួនប៉ុន្មានដែលបង?

ខៈ ដូចជាមួយពាន់។

កៈ ចាំ!មួយពាន់ដុល្លាបង?

ខៈ ចាំ!

កៈ
ចាំ!ហើយចឹងបងបានរៀបការជាមួយគាត់នឹងអស់រយៈពេល១៧ឆ្នាំហើយចាំហើយបន្ទបពីបងបានរៀបការជាមួយគាត់មកតើបងមានកូនប៉ុន្មានអ្នកហើយបង?

ខៈ ខ្ញុំបានកូនពីនាក់។

កៈ ចាំ!ហើយស្រីប៉ុន្មានប្រុសប៉ុន្មានដែលបង?

ខៈ ខ្ញុំបានប្រុសមួយស្រីមួយ។

កៈ
ចាំ!ហើយបងបានរៀបការជាមួយប្តីបងបានតែ១៧ឆ្នាំទេតែបងមានកូនស្រីបានការហើយមានចៅមកទៀត?

ខៈ ខ្ញុំមិនទាន់មានចៅទេ?

កៈ ចាំ!បងមានកូនមកសិនណាស់?

ខៈ ចាំ!

កៈ
ចាំ!ចឹងបងអាចប្រាប់ខ្ញុំបន្ថែមបានទេថាជាមូលហេតុអ្វីបានជាបងបានស្គាល់ស្វាមីរបស់បង?

ខៈ
ខ្ញុំរក់ស៊ីពីមុនខ្ញុំនៅផ្សារកណ្តាលគាត់ថាមិននឹងស្មានថាស្រលាញ់ខ្ញុំទេតែបានមកគាត់នឹងនៅកំសត់កំរកជាមួយគ្នា។

កៈ ចាំ!បងមានប្រវត្តិជួលចត់ដូចគ្នាតើមានប្រវត្តិអ្វីដែលបង?

ខៈ
ខ្ញុំដូចជាផ្លែប៉ោងណាស់គាត់មានតែមួយគាត់អោយខ្ញុំដល់ទៅខ្ញុំថាខ្ញុំមិនញ៉ាំទេគាត់ទុកញ៉ាំទៅដល់ហើយទៅថ្ងៃមួយគាត់មានងងឹតមុខចឹងទៅណាស់ខ្ញុំជួយកោះខ្យលអោយគាត់ហើយខ្ញុំមិនបានធ្វើអ្វីដែលមិនល្អទេ។

កៈ ចាំ!ខ្ញុំយល់ហើយ?

ខៈ
ចាំ!ដល់ទៅខ្ញុំកោះខ្យល់អីអោយគាត់ទៅដល់ហើយខ្ញុំក៏ទៅទិញថ្នាំអីអោយគាត់ដល់ហើយទៅគាត់ដឹងខ្លួនគាត់ក៏អរគុណខ្ញុំហើយគាត់បានទៅប្រាប់ម្តាយគាត់រួចទៅគាត់ក៏មកសួរខ្ញុំ។

កៈ អីចឹងទៅណាធ្វើអោយបងមានភាពកក់ក្តៅចេញពីបងមក?

ខៈ ចាំ!

កះចឹងគាត់បានទៅសុំពីឪពុកម្ដាយរបស់គាត់អោយមកស្ដីដណ្ដិតបងពីឪពុកម្ដាយរបស់បង?

ខះ អត់ទេពីម្ដាយនិងបងប្អូនស្រីរបស់គាត់ទេប៉ាក់គាត់បានស្លាប់អត់ហើយ?

កះ
ចាំចឹងនៅពេលដែលបងបានរៀបការជាមួយគាត់និងជីវិតរបស់មិចដែលដែលបងគាត់យកចិត្តទុកដាក់ចំពោះបងដែលទេកាលគាត់បាននៅរស់និងបង?

ខះ
ជារឿងធម្មតាអត់ដែលពិបាកទេសំរាប់ខ្ញុំនិងគាត់និងបានធ្វើអោយខ្ញុំពិបាកទេរហូតដល់គាត់បានស្លាប់និង។

កះ ចាំបានអោយភាពកក់ក្ដៅដល់ទៅបងស្រីគាត់មិនបានធ្វើអោយពិបាកចិត្តទេ?

ខះ ប៉ុ
ន្តែខ្ញុំគាត់មិនដែលទៅខូចចិលអីទេតែបើគាត់ឈឺអីចេងគាត់មិនដែលប្រាប់ខ្ញុំទេហើយខ្ញុំនិងខ្ញុំចេះតែសួរគាត់ថាប៉ាក់កើតអីនិងខ្ញុំមើលមុនប៉ាកឯងពិបាកមើលម៉េចគាត់បានប្រាប់ខ្ញុំថាគាត់មិនបានកើតអីទេមិនបាច់កោតខ្យល់អោយគាត់ទេចាំគាត់លេមថ្នាំទៅគាត់ទៅគាត់និងបានជាងហើយគាត់ចេះតែទិញថ្នាំរហូតនិយាយរួមទៅគាត់បានទិញថ្នាំនិងតាំងពីកូនខ្ញុំមីបងនិងបានតាំងពីហើយខ្ញុំអត់មាត់ខ្ញុំចាំមើលហើយសង្កេតគាត់ប៉ុន្មានដងទៀតគាត់នៅតែលួចលាក់ហើយថ្ងៃមួយខ្ញុំបានទៅតាមដានគាត់ដល់កន្លែងពេទ្យហើយគាត់បានទៅបាត់ខ្ញុំទៅដល់ពេទ្យគាត់ខ្ញុំបានទៅសួរលោកគ្រូពេទ្យនិងខ្ញុំបានសួរគាត់ថាប្ដីខ្ញុំគាត់បានកើតអីទៅហើយប្ដីខ្ញុំគាត់ជាពួកម៉ាកខ្ញុំទៀតគាត់ជាសមាជិតគាត់បានប្រាប់ខ្ញុំថាប្ដីខ្ញុំឈាមសរសុីឈាមក្រហម។

កះ អឺ!

ខះ គាត់បានលាក់ខ្ញុំរហូតដល់គាត់បានស្លាប់ចោលខ្ញុំមុនបុណ្យភ្ជុំបិន។

កះ
អឺ!ចាំគាត់មិនដែលបានធ្វើអោយបងពិបាកចិត្តទេដោយគាត់បានឈឺនិងគាត់ជាមនុស្សម្នាក់ដែលបានស្រលាញ់ប្រពន្ធកូនមិនចឹងអោយប្រពន្ធពិបាកចិត្តអីចឹងណាបងចឹងគាត់បានលាក់បងរហូតទៅហើយគាត់បានលាក់បងរហូតដល់គាត់បានកូនក្បុងរហូតដល់បានកូនទីពីរនិងទៅកាលនិងខ្ញុំមានកូនទីពីរនិងខ្ញុំអត់ដឹងផងនិងកាលនិងខ្ញុំ។

កះ ឥឡូវនិងកូនបងបានអាយុប៉ុន្មានហើយ?

ខ៖ ខ្ញុំទើបនិងបានកើតនិង។

ក៖
ខ្ញុំទើបនិងកើតក្រោយនិងខ្ញុំទើបនិងមកមើលគាត់មិចនិងចឹងស្វាមីរបស់បងគាត់ទើបនិងបានស្លាប់នៅមុនភ្ជុំនិងទេហើយខ្ញុំក៏សុំទោសផងដែល
ដែលខ្ញុំបានសួរជីវះប្រវិត្តរបស់និងហើយសួរបងចំពេលប្តីបងទើបនិងស្លាប់ទៀត?

ខ៖ អត់អីទេខ្ញុំអត់ប្រកាន់ទេ។

ក៖ ចាំខ្ញុំអរគុណបងចឹងបងទាក់ទង់និងបញ្ហាដទៃទៀតណាបង?

ខ៖ ចាំ

ក៖ ខាងផ្នែកភាសាវិញតើបងបានរៀនភាសាខ្មែរទេពីមុនមកបង?

ខ៖ ខ្ញុំបានរៀននិងតាំងពីខ្ញុំបាននៅពីតូចមក។

ក៖
ចាំចឹងបងបានរៀនកាលពីនៅតូចនែ៎បងហើយកាលបងបាននៅរៀននិងបងបានរៀនត្រឹមកម្រិតវប្បធម៍ត្រឹមណាដែលបង?

ខ៖
ខ្ញុំបានរៀនទិចណាស់កាលនិងបានមើលឃើញម៉ាក់ប៉ាក់ខ្ញុំកាលនិងគាត់ពិបាកណាស់បានខ្ញុំឈប់រៀននិង។

ក៖ ចាំចឹងបងបានរៀនបានទិចទួចណាស់និងបានត្រឹមថ្នាក់ទី១ ២ ៣ ៤ ដែលទេបង?

ខ៖ ខ្ញុំបានរៀនត្រធមថ្នក់ទី២និងកាលនិង។

ក៖ ចាំចឹងបងបានរៀនត្រធមថ្នាក់ទី១ និង២
និងបានចាំថាសាលារៀនបងនិងមានឈ្មោះអីដែលបង?

ខ៖ចាំខ្ញុំមិនបានរៀននៅនិងទេខ្ញុំបានរៀននៅថៃតើ។

ក៖ ចឹងបងបានរៀននៅសាលាបឋមសិក្សានៅថៃទេ?

ខ៖ ចាំ

ក៖ បងនៅនិងបងបានរៀនជាភាសាងថៃឬបងបានរៀនជាភាសាខ្មែរកាលនិងបង?

ខ៖
ខ្ញុំបានរៀនជាភាសខ្មែរនិងកាលនិងខ្ញុំបានរៀននិងនោះដូចជាកាលខ្ញុំបានរៀននិងខ្ញុំរៀនដូចជា ក ខ គ ឃ ងអីនិងកាលនិងនោះ។

ក៖ ចាំកាលបងបានរៀនបងមានបានចាំថាសាលាបងមានឈ្មោះអីដែលបងកាលនិង?

ខ៖ ខ្ញុំបានភ្លេចវាតរៀងយូរហើយខ្ញុំមិនបាននៅចាំទេ។

ក៖
ចាំចឹងអត់អីទេបងហើយមានបានចេះភាសាអីផ្សេងទេតែខ្ញុំបានដឹងថាបងបានចេះភាសាថៃច្រើនហើយបងបានចេះជាងភាសាដ៏ទៃទៀតមែនទេបង?

ខ៖
អត់ទេខ្ញុំនមកដល់ឥឡូវនិងខ្ញុំមិនបានចេះទេកាលពីមុនខ្ញុំអាចចេះឥឡូវនិងខ្ញុំបានភ្លេចអស់ហើយ។

ក៖
កាលបងបានទៅរកស៊ីនៅឯងជាយដែនថៃនិងបងបានចេះភាសាថៃទេបងកាលនិងហើយបងបានចេះភាសាអីផ្សេងៗពីភាសាថៃទេបងហើយបងបានចេះភាសាវៀតណាមបានច្រើនទេបង?

ខ៖ ខ្ញុំបានចេះភាសាវៀតណាមបានច្រើនខ្ញុំបានចេះពាក់កណ្ដាយ។

ក៖
អូបងបានចេះភាសាវៀតណាមបានច្រើនដែលនិងបងដោយសារអីបានបងចេះភាសាវៀតណាមនិង?

ខ៖
ដោយសារតែយាយខ្ញុំនិងគាត់បានចេះភាសាវៀតណាមហើយគាត់និយាយជាមួយខ្ញុំរាល់ថ្ងៃចឹងហើយបានខ្ញុំចាប់បានភាសាវៀតណាមនិងទៅហើយគាត់បាននិយាយអីខ្ញុំបានដឹងទាំងអស់និងប៉ុន្តែគាត់បានស្ដីអោយខ្ញុំអីនិងជាភាសាវៀតណាមនិងខ្ញុំបានដឹងទាំងអ់សំរាប់ខ្ញុំកាលនិង។

ក៖
ចឹងបងដោុសារបងបានចេះភាសាវៀតណាមនិងដោយសារតែបងមានយាយដែលចេះភាសាវៀតណាមនិងណាបងហើយក្រោយមកបងមានដែលបានស៊ីស្នួយធ្វើកាលអោយទេបងកន្លងមក?

ខ៖
កាលនិងខ្ញុំបានធ្វើតើកាលខ្ញុំនៅនិងហើយកាលខ្ញុំនៅលើរនិងខ្ញុំបានធ្វើនិងដែលនិងកាលនិង។

ក៖ ការងារអីដែលបងកាលនិង?

ខ៖ ដូចជាបកខ្ទឹម កាត់ម្ទេស?

ក៖ ហើយកាលនិងបងបានកំលៃបានប៉ុន្មានដែលបងកាលនិង?

ខ៖ កាលនិងខ្ញុំបានតែមួយថ្ងៃបានតែ១៥០០ទេកាលនិងខ្ញុំបានធ្វើអោយគេនិងនោះ។

ក៖ ហើយកាលនិងបងមិនមែនធ្វើម៉ាយបាវធំអោយគេណាបងកាលនិង?

ខ៖ខ្ញុំធ្វើអោយគេបានតែមួយបាវខ្ចៅអោយធំនិងទេកាលនិងខ្ញុំបានធ្វើនិងនោះ។

ក៖ មែនអាបាវស្នាតក្រហមនិងបង?

ខ៖ មិនមេនទេបាវរៀង។

ក៖ ចាំ!ឥឡូវនិយាយចេះបាវរាងមិចដែលបង?

ខ៖ បាវនឹងរាងប្រហែល២០គីឡូរជាងទេ។

ក៖ ចាំ!២០គីឡូរជាងណាស់បង?

ខ៖ ចាំ!ហើយម្ទេសនឹងស្រាលៗទេ។

ក៖ ចាំ!យើងបេះហើយយើងកាត់ទងវាទៅបង?

ខ៖ ចាំ!កាត់យកទងវាចេញ។

ក៖ ចាំ!ហើយកាលនឹងមួយបាវបានតា១៥០០រៀលទេបង?

ខ៖ ចាំ!បានតា១៥០០រៀលទេ។

ក៖ ចាំ!ថោក់ម៉េះមកហើយបងធ្វើការបានប៉ុន្មានឆ្នាំទៅបង?

ខ៖ អត់ទេគេគិតមួយថ្ងៃ។

ក៖
អត់ទេខ្ញុំចង់និយាយថាបងនឹងធ្វើការបេះម្ទេសហើយនឹងខ្ទឹមនឹងបងធ្វើការអោយគេនឹងអស់រយះពេលប៉ុន្មានខែឆ្នាំហើយបង?

ខ៖ ខ្ញុំធ្វើការនៅនឹងបានតា៥ទៅ៦ថ្ងៃ។

ក៖ ចាំ!ហើយបងធ្វើការនៅនឹងបាន៥ទៅ៦ថ្ងៃបានបងបានបើកលុយម្តងមែនបង?

ខ៖ អត់ទេខ្ញុំបើករាល់ថ្ងៃ។

ក៖ ចាំ!ហើយបន្ទាប់ពីបងធ្វើការបកខ្ទឹមនឹងម្ទេសនឹងតើបងមានបានធ្វើការអ្វីទៀតទេបង?

ខ៖ ខ្ញុំរក់ស៊ីខ្លួនឯង។

ក៖ ចាំ!ហើយបងមានអាជីបរក់ស៊ីអ្វីដែលបង?

ខ៖
កាលខ្ញុំបានប្តីខ្ញុំនឹងគាត់ជាអ្នកលក់នៅផ្សារកណ្តាលនឹងដូចជាគាត់លក់ទឹកនឹងភេសះអីទៅតែខ្ញុំជាសមាជិតខ្ញុំអត់ហូបទេ។

ក៖ ចាំ!

ខ៖ គាត់លក់កាហ្វេទឹកសាបអីនឹងគ្រប់សព្វនិយាយរួមទៅហើយនឹង លក់មីឆា លត់ឆា បាយឆា។

ក៖ ចាំហើយបងធ្វើខ្លួនឯងមែនបងឬមួយបងជួលគេ?

ខ៖ ខ្ញុំធ្វើខ្លួនឯង។

ក៖ អរចាំ!ហើយការលក់នឹងបងលក់ដាច់ទេបង?

ខ៖
ខ្ញុំលក់ដាច់តាហើយមួយថ្ងៃៗគាត់រក់បានច្រើនដែលប៉ុន្តែគាត់យកទៅមើលជំងឺគាត់អស់ហើយ។

ក៖ ចាំ!ដោយសារគាត់មានជំងឺចឹងគាត់ត្រូវមើលគាត់វិញហើយបងណាស់?

ខ៖ ចាំ!

កៈ
ចាំ!ហើយចុះទាក់ទងនឹងបងកាលស៊ីឈ្នួលគេនឹងគឺបងជាអ្នកបកខ្ទឹមនឹងអ្នកបកម្ទេសហើយក្រោយមកបងបានប្រកបអាជីបដោយខ្លួនឯងបន្ទាប់ពីបងបានទទួលជីវិត្តមានប្ដីប្រពន្ធអីចឹងណាស់បង?

ខៈ ចាំ!

កៈ
ចាំ!ចឹងបងប្រកបមុខរបរដូចជាអ្នកលក់កាហ្វេនឹងជាអ្នកលក់ភេសៈទិចទួចហើយថែមទែងនឹងបងជាអ្នកលក់មីឆាអីចឹងទៅណាស់បងណាស់ចាំទៅតាមនឹងអ្វីដែលបងបានប្រកបមុខរបរដើម្បីចិញ្ចឹមក្រុមគ្រួសារបងហើយដូចជាតាំងពីតូចមកដល់ធំនឹងតើជីវិត្តរបស់បងនឹងតើមានការផ្លាស់ប្ដូរអ្វីខ្លះទេនៅក្នុងជីវិត្តរបស់បងនឹងបង?

ខៈ
ផ្លាស់ប្ដូរពីមុនខ្ញុំកាចហើយមិនគោរពចាស់ទុំហើយគ្រាន់តែចាស់គេនិយាយតិចចិត្តខ្ញុំនឹងវាឈេឈារ។

កៈ ចាំ!ហើយបងបានទៅស្ដីអោយគេវិញ?

ខៈ ចាំ!តាំងពីខ្ញុំមិនទាន់ជាសមាជិត។

កៈ
ចាំ!ដល់ពេលក្រោយមកបងបានផ្លាស់ប្ដូលច្រើនចាំហើយបងបានផ្លាស់ប្ដូរអ្វីខ្លះដែលបង?

ខៈ ផ្លាស់ប្ដូរដូចជាអ្វីដែលខ្ញុំនិយាយគឺនិយាយអ្វីដែលខ្ញុំមិននិយាយគឺមិននិយាយ។

កៈ
ចាំ!ហើយបងបានផ្លាស់ប្ដូរទៅជាមនុស្សម្នាក់ដែលស្លូតហើយនឹងចេះជួយទុកធូរៈអ្នកដទៃណាស់បងចាំចឹងហើយបងមានបញ្ហាមួយទៀតណាស់បងតើម្ហូបដែលបងចូលចិត្តញ៉ាំជាងគេគឺម្ហូបមួយណាដែលបង?

ខៈ និយាយរួមទៅគឺសំម្លលកកូរ លុកលាក់ ស្ងោម្ជូរ ឆាម្លេះ
ចាំខ្ញុំចូលចិត្តតាប៉ុន្មានមុខនឹងទេ។

កៈ អរចាំ!ដូចជាសំម្លលខ្មែរយើងដូចជាសំម្លល កកូរ សំម្លេះអីអត់ទេបង?

ខៈ ចូលចិត្តតា។

ក៖ ចាំ!តែមួយនឹងបងមានចំណូលខ្លាំងជាងគេចាំដូចជា ឆាម្លេះ លុកលាក់បងចូលចិត្តជាងគេចាំចឹងតើបងកាលនៅពីក្មេងមកតើបងចូលចិត្តលេងល្បែងប្រជាប្រិយដូចជា បោះឈូង ទាញព្រាត់ បោះអង្គុន អីទេបង?

ខ៖ អត់ទេ។

ក៖ ចាំ!ហើយបងចូលចិត្តអ្វីវិញបង?

ខ៖ ខ្ញុំចូលចិត្តរាំ។

ក៖ អរចាំ!បងចូលចិត្តរាំជាងហើយបងច្រៀងទៀតណាស់បង?

ខ៖ បើលច្រៀងខ្ញុំមិនបស្ូវចេះប៉ុន្មានទេ។

ក៖ ចាំ!តែបងពិនរាំជាង?

ខ៖ ចាំ!ហើយខ្ញុំមានបងប្អូនជីដូនមួយខ្ញុំមួយនឹងគាត់ចេះច្រៀងឥឡូវគេជាដារា។

ក៖ ចាំ!ហើយគាត់មានឈ្មោះអ្វីដែលបង?

ខ៖ គាត់មានឈ្មោះថា កែវ សុខបញ្ញា។

ក៖ ចាំ!គាត់ឈ្មោះ កែវ សុខបញ្ញាគេជាដារាហើយនឹងហើយបងចេះរាំអីដោយសារទៅតាមប្អូនជីដូនមួយ?

ខ៖ អត់ទេខ្ញុំចេះខ្លួនឯង។

ក៖ ចាំ!បងចេះខ្លួនឯងនឹងហើយបងជាមនុស្សម្នាក់ដែលពូកែខាងរាំតែបងមិនចេះច្រៀងទេមិនចេះអ្វីទាំងអស់ហើយខាងផ្នែកកីឡាបងចូលចិត្តលេងខាងផ្នែកកីឡាអ្វីជាងគេបង?

ខ៖ ខ្ញុំចូលចិត្តកីឡាខាងផ្នែកទាត់បាល។

ក៖ ចាំ!បងខាងផ្នែកទាត់បាលចាំហើយពីមុនមកតើបងបានលេងទេបង?

ខ៖ ពីមុនមកខ្ញុំធ្លប់តែឥឡូវខ្ញុំអត់ទេ។

ក៖ ចាំ!ឥឡូវបងទាត់មិនបានទេព្រោះបងកូនខ្ចីហើយចាំចឹងទាក់ទងនឹងបញ្ហាមួយទៀតណាស់បងចាំដូចជាក្រុមគ្រួសាររបស់បងនឹងណាស់ទាំងកូនខ្ទួយក៏ដោយដូចជាប្អូនក៏ដោយបើល

សិចជាក្រុមគ្រួសារបងទាំងអស់នឹងតើមាននាក់ណាដែលគេចេះលេងភ្លេងដូចជា រណៀត ចាប៉ី ហ្គីតា នឹងទ្រូរទេបង?

ខ៖ មានតាអាមួយមិននឹង។

ក៖ ចា៎!ក្មួយនឹងមែនបង?

ខ៖ ចា៎!

ក៖ ក្មួយដែលដើរមកមិននឹងបងតើគាត់ចេះលេងភ្លេងខាងផ្នែកណាដែលបង?

ខ៖ គាត់នៅខាងភ្លេង។

ក៖ ចា៎!តែភ្លេងវាមានភ្លេងច្រើនណាស់បងដូចជាភ្លេងសម័យដូចជាភ្លេងការ?

ខ៖ គាត់ខាងភ្លេងការ។

ក៖ អរចា៎!គាត់ជាអ្នកខាងហ្គីតាចា៎ដូចជាក្មួយបងបង្កើត?

ខ៖ ចា៎!

ក៖ ជាកូនបងស្រីរបស់បងមែនបង?

ខ៖ កូនខាងបងប្រុស។

ក៖
ចា៎!ខាងបងប្រុសវិញចា៎ហើយអ្នកដែលចេះលេងភ្លេងមិននឹងតើគាត់មានឈ្មោះអ្វីដែលបង
?

ខ៖
មិននឹងមិនដឹងវាមានឈ្មោះអីទេព្រោះវាជាកូនភ្លូសណាស់មិនអារ៉ន់មិនដឹងអាម៉េចមិនដឹង
។

ក៖
អរចា៎!គាត់ជាកូនភ្លូសហើយបងមិនដឹងថាគាត់ជារ៉ាន់ហើយមិនដឹងថាគាត់ជាម៉េតទេដោយ
សារពួកគាត់ជាកូនភ្លូស?

ខ៖
អរមិនគាត់ឈ្មោះរ៉ន់អាម៉េចវាមិនចូលចិត្តទេវាចូលចិត្តលេងកំផ្លែងអោយយើងសើតទៅ
ណាស់។

កៈ
ចា៎!ចឹងតើផ្ទះរបស់បងកាលបងនៅជាមួយឪពុកម្តាយរបស់បងកាលបងនៅតាំងពីក្មេងមករហូតដល់ធំណាស់បងតើផ្ទះមិចដែលបង?

ខៈ និយាយរួមទៅផ្ទះឈើហើយពីមុនខ្ញុំខាងនោះ។

កៈ ចា៎!

ខៈ
ដូចថាខ្ញុំនៅជាមួយយាយមានបញ្ហាអីចឹងទៅវាបែលទៅជានិយាយទៅវាពិបាកណាស់។

កៈ
ហើយបងក៏បែកគំនិតចេញមកចា៎ចឹងបងអាចប្រាប់ខ្ញុំបន្ថែមទៀតបានទេថាតើផ្ទះដែលបងបានរស់នៅជាមួយលោកឪពុកម្តាយរបស់បងតាំងពីបងនៅពីក្មេងមករហូតដល់ធំផ្ទះរបស់បងគឺជាផ្ទះឈើហើយដំបូលតើបងធ្វើអំពីអ្វីដែលបង?

ខៈ អរពីមុនដែលខ្ញុំនៅជាមួយប៉ាម៉ាក់ខ្ញុំមែន។

កៈ ចា៎!

ខៈ គាត់មានតាផ្ទះស្លឹកទេ។

កៈ ចា៎!ផ្ទះស្លឹកទេចា៎ហើយដូចជាផ្ទះស្លឹកនឹងដូចជាផ្ទះមិចទៅបង?

ខៈ នៅជំរុមនឹង។

កៈ នៅជំរុមហើយផ្ទះរបស់បងធ្វើអំពីស្លឹកដំបូលស្លឹកហើយជញ្ជាំងបង?

ខៈ បើលជញ្ជាំងវិញគាត់ធ្វើរបៀបក្តារ។

កៈ
ចា៎!ប៉ុន្តែក្រោយមកបងបានផ្លាស់មកនៅពីក្រុងភ្នំពេញផ្ទះនឹងផ្ទះដំបូងរបស់បងយ៉ាងមិនដែលបង?

ខៈ ផ្ទះដំបូងគេឈើហើយបន្ទាប់មកផ្ទះថ្ម។

កៈ ចា៎!បងមកនៅនឹងរហូតមកគឺផ្ទះថ្មហើយតើបងជួរគេធ្វើឬមួយបងធ្វើខ្លួនឯងដែលបង?

ខៈ ខ្ញុំជួរគេធ្វើ។

ក៖ អរចាំ!

ខ៖ ខ្ញុំជួរគេធ្វើតា។

ក៖
ចាំ!បងអត់បានធ្វើខ្លួនឯងទេចាំចឹងបងអាចប្រាប់ខ្ញុំបន្ថែមបានទេថាតើបងមានបានចេះជំនាញអ្វីខ្លះដែលទាក់ទង់នឹងក្រុមគ្រួសារបងដែលបងបានរៀនណាស់ដូចជាការធ្វើស្កររត្នោតសិប្បកម្មដំប្បាញ សិប្បកម្មវិញខ្សែព្ររ នឹងធ្វើតុកពីដំណៀកផ្ដៅចឹងណាស់បង?

ខ៖ ខ្ញុំអត់ចេះទេ។

ក៖ ចាំ!បងមិនចេះទាំងអស់ចាំចឹងបងចេះអ្វីដែលបន្តវេណាពីក្រុមគ្រួសារបងដែលបង?

ខ៖ និយាយរួមទៅខ្ញុំមិនចេះធ្វើអ្វីទេចេះតែលក់ដូរ។

ក៖
ចាំ!បងចេះតែលក់ដូរទេចាំអ្វីដែលបន្តវេណាពីក្រុមគ្រួសារបងគឺបងចេះតែលក់ដូរនឹងទេចាំចឹងបញ្ហាដែលនៅក្នុងជីវិត្តរបស់បងណាស់តើមានបញ្ហាអ្វីខ្លះដែលបងបានជួបឧបសគ្គន៍នៅក្នុងជីវិត្តរបស់បងដែលបងធ្លាប់ឆ្លងកាត់មកណាស់តើបងមានអ្វីខ្លះដែលបង?

ខ៖ និយាយរួមទៅខ្ញុំធ្លាប់ឆ្លងកាត់ការពីបាកតាំងពីតូចមែន។

ក៖ ចាំ!តាំងពីតូចរហូតមកដល់សព្វថ្ងៃនឹងណាស់បង?

ខ៖
ខ្ញុំធ្លាប់ពិបាកនឿយហាត់មើលប្អូនហើយនឹងធ្វើអីនៅផ្ទះនឿយណាស់ទុបតែឥឡូវរាងស្រណុក។

ក៖
ចាំ!ដោយសារពីក្មេងមកបងចាប់ផ្ដើមជួយធ្វើការលោកឪពុកម្ដាយអីចឹងណាស់ចាំចឹងបានបងបានដឹងថាមានជីវិត្តបែបណាថានឿយណាស់ចាំតែឥឡូវបងលែងនឿយហើយបងស្រណុកហើយសប្បាយចិត្តហើយសប្បាយរាល់ថ្ងៃ?

ខ៖ ចាំ!

ក៖
ចាំ!ចឹងតើបងមានអ្វីដែលបងពង់ប្រាថ្នារបស់បងណាស់តើបងមានធ្លាប់ពង់ចង់ធ្វើកិច្ចការអ្វីមួយដែលនៅក្នុងជីវិត្តរបស់បងណាស់?

ខ៖
ខ្ញុំពង់អ្វីមួយខ្ញុំមានពង់អ្វីទេខ្ញុំពង់តារក់ស៊ីមួយហើយបានលុយនឹងមកខ្ញុំសន្សំអោយកូនរបស់ខ្ញុំ។

ក៖
ចា៎!សន្សំទុកអោយកូនណាស់បងនឹងហើយជាបំណងពង់ប្រាថ្នាថាដូចជាយើងខំប្រឹងរកពីក្មេងចឹងមកសល់ច្រើនចឹងមកដល់ពេលដែលយើងចាស់ទៅយើងទយកគេរអោយកូនរបស់យើងចា៎ទ្រព្យសម្បត្តិដែលដែលយើងខំរកមកទាំងប៉ុន្មានណាស់ចា៎ដើម្បីអោយកូនមានភាពគក់ក្តៅដូចជាមានលុយកាក់ខ្លួនឯងសំរាប់គេប្រើលប្រាស់សំរាប់អនាគតរបស់គេចឹងណាស់បងចា៎ចឹងជាចុងក្រោយតើបងមានអ្វីដែលបងផ្តៅភ្ញើលទៅដល់កូនចៅជំនាន់ក្រោយដូចជាអោយពួកគេខំប្រឹងរៀនឬមួយពួកគេធ្វើការអោយពួកគេធ្វើដោយអស់ពីចិត្តណាស់បង?

ខ៖
ចា៎!ខ្ញុំសូមផ្តែផ្តៅមួយសូមកុំអោយផ្លើតផ្លើនមួយដូចជាផឹកស្រានិយាយរួមទៅជក់ម៉ារអីចឹងគឺខ្ញុំមិនចូលចិត្តទេ។

ក៖ ចា៎!គឺខាងគ្រឿងញៀញណាស់បង?

ខ៖
ចា៎!មួយនឹងគឺខ្ញុំមិនចូលចិត្តទាំងអស់ព្រោះខ្ញុំខូចចិត្តមួយហើយជីដូនមួយខ្ញុំបង្កើតជាកូនពូរខ្ញុំនេះវាបានសេពគប់គ្រឿងញៀញហើយវាបានវៃឪពុកទុបតាស្លាប់ប៉ុន្មានថ្ងៃនឹងទេតាំងពីខ្ញុំសំរាលកូនខែ១០នឹងខែ៣។

ក៖ ចា៎!ចឹងមានន័យថាគាត់ទុបតែសម្លាប់លោកឪពុកគាត់ទុបតែរួចទេ?

ខ៖ ចា៎!

ក៖ ចា៎!ចឹងជាក្មួយជីដូនមួយសាច់ឆ្ងៃ?

ខ៖ អត់ទេខាងប្អូន។

ក៖ ចា៎!ខាងប្អូនជីដូនមួយសាច់ឆ្ងៃបង?

ខ៖ អត់ទេបង្កើត។

ក៖
អរចា៎!ប្អូនជីដូនមួយបង្កើតណាស់បងចា៎ហើយបងសូមផ្តៅផ្ញើលអោយកូនជំនាន់ក្រោយនឹ

ងគឺអោយគាត់ជៀសវាងពីគ្រឿងញៀញការដើរផឹកស៊ីមិនល្អចាំហើយមិត្តភក្តិណាមិនល្អក៏កុំរាប់អានចឹងណាស់បងដូចជាកុំសេពគប់អីចឹងទៅណាស់បង?

ខ៖ ចាំ!

ក៖
ចាំ!ហើយចុះការសិក្សាឬមួយគាត់ធ្វើការតើបងមានអ្វីដែលត្រូវផ្តែផ្តៅបែបណាដែលបង?

ខ៖
ខ្ញុំផ្តែផ្តៅខាងធ្វើការវិញបើលយើងនិយាយពីការរៀនគេមិនយកចិត្តទុកដាក់ខ្ញុំពិបាននិយាយជាមួយគេរឿងនឹង។

ក៖ ចាំ!

ខ៖ ហើយខ្ញុំមានក្មួយខ្ញុំ៥នាក់នៅទីនេះពិនតែគេអត់មានទៅដើរលេងអីចឹងទេ។

ក៖ ចាំ!ដោយសារគាត់ជាមនុស្សល្អ?

ខ៖ នេះខ្ញុំមើលគំនូរក្មួយរបស់ខ្ញុំហើយខ្ញុំធ្វើគនូរល្អសំរាប់ខ្ញុំ។

ក៖
ចាំ!ចឹងជាគោរបំណងរបស់បងដែលបងបានពងប្រាថ្នាទៅថ្ងៃអនាគត់របស់បងនឹងការផ្តែផ្តៅទៅថ្ងៃអនាគត់របស់បងណាស់ចាំចឹងបងមានអ្វីដែលនិយាយទៀតទេបង?

ខ៖ អត់ទេខ្ញុំអស់អីនិយាយហើយ។

ក៖
ចាំ!ចឹងជាចុងក្រោយខ្ញុំសូមអរគុណបងដែលបងបានចំណាយពេលវេលាសំរាប់ខ្ញុំដែលអោយខ្ញុំបានសំភាសន៍អំពីខ្សែរជីវិត្តរបស់សំរាប់អោយសាលា( ប៊ី វ៉ាយ យូរ )ផងដែលនឹងហើយសូមអោយបងមានសុខភាពល្អសូមអោយឆ្នាំថ្មីនេះអោយបងមានការរក់ស៊ីទទូលនូវការរកស៊ីមានបានហើយសូមអោយបងមានការរីកចំរើនពីមួយថ្ងៃទៅមួយថ្ងៃផងដែលចាំហើយខ្ញុំសូមជំរាបលាហើយសំរាប់ក្មេងៗដែលជំនាន់ក្រោយណាស់បងហើយនៅពេលដែលគេបានបើកបានឮសំលេងបងហើយស្តាប់ឮទៅគេនឹងដឹងថាបងផ្តៅផ្ញើលនូវអ្វីខ្លះហើយនឹងការជៀសវាងអ្វីខ្លះនៅពេលដែលចាស់ទុំជំនាន់មុននឹងគេផ្តៅផ្ញើលទៅអោយក្មេងជំនាន់ក្រោយណាស់បងណាស់ចាំចឹងខ្ញុំសូមអរគុណបង។